00896427

លេខ: D126

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 04 / 2013
ម៉ោង (Time/Heure): 09:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

**លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/ស.ច.ស.ច.ស--ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | **ចៅក្រម យូ ប៊ុនឡេង** |
| | **ចៅក្រម Mark B. HARMON** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣** |
| ភាសាដើម ៖ | **អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សាធារណៈ(ឯកសារកោសលុប)** |

# សេចក្តីសម្រេចទទួលស្គាល់មេធាវីទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤

**ផ្ញើជូន**

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ចម្លងជូន៖**
អង្គភាពគាំពារជនរងគ្រោះ
CHOUNG Chou Ngy
Mahdev MOHAN

**ជូនដំណឹង**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Philippine SUTZ

1. **បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

2. **បានឃើញ** វិធាន ២១, ២៣, ២៣ស្ទួន, ២៣ស្ទួន២ និង ៧២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី ៨ (វិធានផ្ទៃក្នុង)។

3. **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង០០៤[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[២]។

4. **បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងបទចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** ការរំលោភបំពានលើ**អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥, ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦) ។

5. **បានឃើញ**ថា ចាប់តាំងពីថ្ងៃចេញសេចក្តីសម្រេចនេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៧៦០ ត្រូវបានទទួលដោយសហចៅក្រមស៊ើបអង្កេត ហើយកំពុងស្ថិតនៅក្នុងដំណើរការដាក់ចូលទៅក្នុងសំណុំរឿង រួមទាំងលិខិតផ្ទេរសិទ្ធិ ដែលចាត់តាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសរុប ចំនួន ២១ នាក់ ជាមេធាវីក្នុងសំណុំរឿង ០០៤ ហើយអង្គភាពគាំពារជនរងគ្រោះ បានជូនដំណឹងថាមេធាវីទាំងនោះមានគុណវុឌ្ឍិនៅចំពោះមុខអ.វ.ត.ក[៣]។

---

[១] សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[៣] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ក៏បានចាត់តាំង CHOUNG Chou-Ngy ឬ Mahdev MOHAN ជាមេធាវីរបស់ពួកគាត់ ទោះបីយ៉ាងណា លិខិតផ្ទេរសិទ្ធិដែលមានសុពលភាពមិនទាន់ត្រូវបានទទួលបានដោយក្រឡាបញ្ជីនៃ ក.ស.ច.ស នៅក្នុងសំណុំរឿង០០៤ ឡើយ។

00896429



6. **បានឃើញ**ថា នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ **[កោសលុប]** នៅក្នុងសំណុំរឿង ០០៤ ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត[៤] ដូច្នេះ ហើយនៅតែមាននៅក្នុងសំណុំរឿងសម្ងាត់នេះក្នុងនាមជាអ្នកប្តឹង ប្រសិនបើគ្មានសំណើផ្ទុយពីនេះ។

7. **បានឃើញ**ថា នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នេះដែរ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់**[កោសលុប]**នៅក្នុងសំណុំរឿង ០០៤ ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត[៥]។ សំណើសុំឱ្យពិចារណាឡើងវិញទៅលើសេចក្តីសម្រេចស្តីពីលទ្ធភាពទទួលស្គាល់ **[កោសលុប]** នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានដាក់ចូលនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ (សំណើស្នើសុំឱ្យពិចារណាឡើងវិញ**[កោសលុប]**[៦])។ បន្ទាប់ពីបានត្រួតពិនិត្យឡើងវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានទទួលស្គាល់គាត់ ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ហើយ បានបញ្ជាក់ថា "ពាក្យសុំតាំងខ្លួន

---

[៤] អ.វ.ត.ក, ស.ច.ស, សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D5/1/3 *ដីកាស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់*[កោសលុប]ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ ការបដិសេធនេះត្រូវបានតម្កល់ទុកដោយអង្គបុរេជំនុំជម្រះ ពីព្រោះថាមិនអាចរកសម្លេងភាគច្រើនលើសលុប៖ អ.វ.ត.ក,អ.ប.ជ(០១) សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារD5/4/2 *ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់*[កោសលុប]ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

[៥] អ.វ.ត.ក, ស.ច.ស, សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D5/2/3 *ដីកាស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់* [កោសលុប] ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ ការបដិសេធនេះត្រូវបានតម្កល់ទុកដោយអង្គបុរេជំនុំជម្រះ ពីព្រោះថាមិនអាចរកសម្លេងភាគច្រើនលើសលុប៖ អ.វ.ត.ក,អ.ប.ជ(០១) សំណុំរឿង០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារD5/2/4/3 *ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់*[កោសលុប] ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២។

[៦] *សំណើសុំឱ្យ សហចៅក្រមស៊ើបអង្កេត ពិចារណាឡើងវិញទៅលើដីកាស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់*[កោសលុប] (ឯកសារ D11/2/3)(សំណុំរឿង ០០៣ និង ០០៤) សំណុំរឿង ០០៣/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D11/2/5 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១(មិនស្ថិតនៅក្នុងសំណុំរឿង ០០៤)។

ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងសំណុំរឿង ០០៤ នឹងត្រូវពិចារណាដាច់ដោយឡែក"[៧]។ ទោះបីយ៉ាងណា សំណើស្នើសុំឱ្យពិចារណាឡើងវិញ[**កោសលុប**] មិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ០០៤ ឡើយនៅពេលនោះ។

8. **បានឃើញ** ទៀតថា នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ លោកស្រី Silke Studzinsky មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានជូនដំណឹងពីការលាលែងតំណែងរបស់លោកស្រី ជាមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងការផ្ទេរសិទ្ធិរបស់គាត់តំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ ជូនទៅលោកស្រី Lyma NGUYEN (លិខិតលាលែងតំណែងរបស់លោកស្រី Silke Studzinsky)[៨]។

9. **បានឃើញ**ថា យោងតាមវិធាន ២៣ស្ទួន (២) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី "លើកលែង និងលុះតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល" ហើយមិនមានលក្ខខណ្ឌតម្រូវនៅក្នុងវិធាននេះដែលថាត្រូវមានការចោទប្រកាន់ជាផ្លូវការមុនពេលដែលសិទ្ធិនេះអាចត្រូវអនុវត្តឡើយ ចំណែកឯ វិធានផ្ទៃក្នុង ២៣ស្ទួន២(១) ណែនាំឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាសមស្របនានាសម្រាប់គោលបំណងធានាឱ្យមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមពេលវេលាសមរម្យ តាមដែលអាចអនុវត្តទៅបាន។

10. **បានឃើញ**ថា ឆន្ទានុសិទ្ធិស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត គឺជាភារកិច្ចមួយច្បាស់លាស់ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(៥)ដែល *"ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ"* ហើយភារកិច្ចនេះ ក៏ការពារសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការស៊ើបសួរពិតប្រាកដ ដូចបានបញ្ជាក់ដោយវិធានផ្ទៃក្នុង ២១ អនុវិធាន ១(ក) និង(គ)។

---

[៧] អ.វ.ត.ក, ស.ច.ស.អ.ប, សំណុំរឿង ០០៣/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D11/2/5/1 ដីកាស្តីពីការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[**កោសលុប**] ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣៨។

[៨] សំណុំរឿង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D125 *ការលះបង់សិទ្ធិតំណាងកូនក្តីក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ របស់លោកស្រី Silke Studzinsky និងការផ្ទេរសិទ្ធិតំណាងកូនក្តីរបស់ខ្ញុំនៅក្នុងសំណុំរឿង* ០០៣ និង ០០៤ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣។

11. **ដោយពិចារណា**ថា ដើម្បីការពារប្រយោជន៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងធានាឲ្យមានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធានផ្ទៃក្នុង២១[9] ខណៈដែលរង់ចាំសេចក្តីសម្រេចលើការទទួលស្គាល់ ឬការត្រួតពិនិត្យឡើងវិញលើសេចក្តីសម្រេចមុនៗស្តីពីការទទួលស្គាល់នោះ គឺសំខាន់ត្រូវបញ្ជាក់ពីស្ថានភាពនៃមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៤។

12. **បានឃើញ**ថា សិទ្ធិ និងកាតព្វកិច្ចខាងក្រោមនេះយកមកអនុវត្តជាលទ្ធផលនៃការចាត់តាំងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖

- **ចូលរួមក្នុងការស៊ើបអង្កេត៖** មេធាវីដែលត្រូវបានទទួលស្គាល់ មានសិទ្ធិអំណាចតំណាងកូនក្តីរបស់ខ្លួនក្នុងអំឡុងពេលចូលរួមកិច្ចស៊ើបសួរ និងដំណើរការនីតិវិធីបុរេជំនុំជម្រះ ដូចបានបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក និងសេចក្តីសម្រេចពាក់ព័ន្ធណាមួយរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ។

- **លទ្ធភាពចូលទៅពិនិត្យសំណុំរឿង៖** មេធាវីដែលត្រូវបានទទួលស្គាល់ មានសិទ្ធិពិនិត្យ និងថតចម្លងឯកសារដើមនៃសំណុំរឿងស្តីពីការស៊ើបអង្កេត ដែលកូនក្តីរបស់ខ្លួនជាភាគីម្នាក់ ព្រមទាំងឯកសារថតចម្លងជាក្រដាស នៅក្នុងអំឡុងថ្ងៃធ្វើការ ហើយត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការប្រព្រឹត្តទៅដ៏ត្រឹមត្រូវនៃអ.វ.ត.ក។ លទ្ធភាពចូលតាមប្រព័ន្ធអេឡិចត្រូនិក អាចត្រូវរៀបចំ*តាមសំណើ* (សូមមើល ឧបសម្ពន្ធ **ខ**[10])ដោយមានជំនួយពីអង្គភាពជនរងគ្រោះ ឬមន្ត្រីសំណុំរឿង ប៉ុន្តែនៅតែស្ថិតនៅក្រោមការត្រួតពិនិត្យជារួមពីក្រឡាបញ្ជីរបស់សហចៅក្រម

---

[9]ទាក់ទងនឹងតម្រូវការឲ្យមាន"យុត្តិធម៌ទៅតាមនីតិវិធី"សម្រាប់ភាគីទាំងអស់នៅក្រោមវិធានផ្ទៃក្នុង២១ រួមបញ្ចូលការគោរពសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមជាភាគីនៅក្នុងកិច្ចស៊ើបសួរ "លើកលែងនិងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល" យោងតាមវិធាន ២៣ស្ទួន (២) សូមមើល អ.វ.ត.ក, អ.ប.ជ, សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/អ.ប.ជ ឯកសារលេខ D5/2/4/3 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*[កោសលុប]*យោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing* ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៥ និង ១០។

[10] ទម្រង់សំណើតាម Zylab ក៏អាចទទួលបានពីក្រឡាបញ្ជីនៃ ក.ស.ច.ស ឬផ្នែកគ្រប់គ្រងតុលាការ ហើយគួរត្រូវផ្ញើទៅក្រឡាបញ្ជីរបស់ក.ស.ច.ស បន្ទាប់មកបញ្ជូនបន្តទៅមន្ត្រីសំណុំរឿង/អង្គភាពបណ្ណសារដើម្បីដំណើរការ ។

ស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ តាមករណីសមស្រប។ ដោយមានហេតុផលសមរម្យ មេធាវីដែលត្រូវបានទទួលស្គាល់ អាចធ្វើការថតចម្លង ឬស្នើសុំឯកសារថតចម្លងដែលមាននៅក្នុងសំណុំរឿង ហើយយកទៅពិគ្រោះពិភាក្សាជាមួយកូនក្តីរបស់ខ្លួន ប៉ុន្តែមិនត្រូវប្រគល់ឯកសារថតចម្លងបែបនោះឲ្យទៅកូនក្តីរបស់ខ្លួន និងជនផ្សេងទៀតឡើយ។

- **ការសម្ងាត់ខាងវិជ្ជាជីវៈ និងតុលាការ៖** តាមរយៈការចូលរួមរបស់កូនក្តីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ទាំងមេធាវីដែលត្រូវបានទទួលស្គាល់ និងកូនក្តីរបស់ខ្លួន នឹងមានលទ្ធភាពចូលទៅពិនិត្យព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿង។ មានតែចៅក្រម និងសហព្រះរាជអាជ្ញានៃអ.វ.ត.ក ប៉ុណ្ណោះដែលអាចសម្រេចធ្វើឲ្យព័ត៌មានបែបនោះទៅជាព័ត៌មានសាធារណៈ។ មេធាវីដែលត្រូវបានទទួលស្គាល់ ជាប់កាតព្វកិច្ចគោរពតាមគោលការណ៍រក្សាការសម្ងាត់នៃការស៊ើបអង្កេត និងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដោយមិនត្រូវលាតត្រដាងព័ត៌មានណាដែលខ្លួនទទួលបានដោយសារបានពិគ្រោះពិភាក្សាទៅលើសំណុំរឿងឡើយ។

- **ការដាក់ឯកសារ៖** ឯកសារផ្លូវការទាំងអស់ត្រូវតែដាក់តាមរយៈក្រឡាបញ្ជីនៃសំណុំរឿង ដូចបានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ នៅពេលដែលលទ្ធភាពតាមអេឡិចត្រូនិកត្រូវបានរៀបចំរួចភ្លាម មេធាវីដែលត្រូវបានទទួលស្គាល់ នឹងទទួលបានការជូនដំណឹងតាមអេឡិចត្រូនិកស្តីពីឯកសារដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ហើយគួរតែផ្តល់អាសយដ្ឋានអ៊ីម៉ែលជូនទៅក្រឡាបញ្ជីរបស់ក.ស.ច.ស សម្រាប់គោលបំណងដើម្បីទទួលបានការជូនដំណឹងនេះ។ ការផ្តល់ជូនឯកសារច្បាប់ថតចម្លងរឹង នឹងអាចផ្តល់ជូនបានក្នុងករណី ដែលមេធាវីដែលត្រូវបានទទួលស្គាល់មិនមានលទ្ធភាពប្រើប្រាស់អ៊ីម៉ែលតែប៉ុណ្ណោះ[11]។

13. **បានឃើញ**ថានៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Harmon បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាទាក់ទងនឹងសេចក្តីសម្រេចទទួលស្គាល់នេះ។

---

[11]វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តន៍ ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក អាចយកមកពិគ្រោះយោបល់ និងទាញយកបានពីគេហទំព័រផ្នែកអង្គភាពគាំពារជនរងគ្រោះ (http://www.eccc.gov.kh/)។ ប្រសិនបើត្រូវការយោបល់បន្ថែមទាក់ទងនឹងមេធាវីតំណាងកូនក្តីនៅក្នុងកិច្ចដំណើរការនីតិវិធីអ.វ.ត.ក សូមទាក់ទងអង្គភាពគាំពារជនរងគ្រោះ។

**អាស្រ័យហេតុនេះ ខ្ញុំ Mark B.Harmon សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ៖**

14. **ផ្តល់នីតិសម្បទា និងទទួលស្គាល់** មេធាវីចំនួន ២០ នាក់ ដែលត្រូវបានទទួលស្គាល់ត្រឹមត្រូវនៅក្នុងបញ្ជីមេធាវីដែលមានបំណងតំណាងជនរងគ្រោះនៅចំពោះមុខអ.វ.ត.ក ដូចមាននៅក្នុងឧបសម្ពន្ធ១ (មិនរាប់បញ្ចូលលោកស្រី Sike studzinsky) ជាមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ នាក់ ដូចមានបង្ហាញជូននៅក្នុងនោះ និងជាតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមណ្តឹងរដ្ឋប្បវេណីផ្សេងទៀតទាំងអស់ដែលកំពុងរង់ចាំ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ ហើយបានចាត់តាំងពួកគាត់ ឬអាចចាត់តាំងពួកគាត់នៅពេលអនាគតសម្រាប់គោលបំណងនៃការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក នៅក្នុងសំណុំរឿង ០០៤។

15. **ណែនាំឲ្យ** ក្រឡាបញ្ជីរបស់ ក.ស.ច.ស៖

- កត់សម្គាល់លើការចាត់តាំងបន្ថែមបែបនេះនៅក្នុងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរួចស្រេចហើយនៅក្នុងសំណុំរឿង។
- ផ្តល់លទ្ធភាពចូលទៅពិនិត្យសំណុំរឿងដល់មេធាវីដែលត្រូវបានទទួលស្គាល់ នៅពេលដែលទទួលបានសំណើតាម Zylab តាមទម្រង់ត្រឹមត្រូវដូចបានបង្ហាញជូនខាងលើ។

16. **សូមឲ្យ** អង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក បន្តទទួលយក និងបញ្ជូនបន្តទៅ ក.ស.ច.ស នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗដែលខ្លួនអាចទទួលបានរហូតដល់រយៈពេល ១៥ថ្ងៃ បន្ទាប់ពីពេលចេញផ្សាយការជូនដំណឹងបន្ថែមតាមវិធាន ៦៦ ស្តីពីការបិទការស៊ើបសួរនៅក្នុងសំណុំ រឿង ០០៤។

17. **សម្រេច** ដាក់សំណើសុំឲ្យពិចារណាឡើងវិញ[**កោសលុប**]ចូលទៅក្នុងសំណុំរឿង ០០៤ ហើយឆ្លើយតបទៅនឹងសំណើនេះយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបានបន្ទាប់ពីបានត្រួតពិនិត្យឡើងវិញលើលក្ខខណ្ឌទទួលស្គាល់ដែលអនុវត្តបាននៅក្នុងសំណុំរឿងនេះ។

០០៤/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស លេខ: D126

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣

**Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co-Investigating Judge**
**Co-juge d'instruction international**